**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០២២.....សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការផ្តល់ទឹកប្រាក់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភជូនគណៈកម្មការអន្តរក្រសួង ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលផល_អនុផលព្រៃឈើ

*********

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខនស / រកម/០៥០៨/០១៦ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន

វិលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
.92. Sangkat Wat Phnom . khan Daun Penh. Phnom Penh. CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៣ លើលិខិតលេខ ៨១២៩ សហវ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០០២ ប្រក.បស្ថ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីចុះពិនិត្យវាយតម្លៃផល-អនុផលព្រៃឈើ របស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**ប្រការ១ :**

ត្រូវបានអនុញ្ញាតឱ្យគណៈកម្មការអន្តរក្រសួងដែលបំពេញភារកិច្ចផ្ទាល់ ចុះធ្វើការវាស់វែង ត្រួតពិនិត្យបរិមាណ និងវាយតម្លៃឈើ កាត់ទុកប្រាក់ចំណូលដែលបានពីសួយសារផល-អនុផលព្រៃឈើនៅលើដីសម្បទានសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានចំនួន ៣% ( បីភាគរយ ) សម្រាប់ជាប្រាក់រង្វាន់លើកទឹកចិត្ត និងសម្រាប់ពង្រឹងយន្តការនៃការងារគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងនៅសល់ចំនួន៩៧%( កៅសិបប្រាំពីរភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

**ប្រការ២ :**

ប្រាក់រង្វាន់ចំនួន ៣% នៃប្រាក់ចំណូលលើការប្រមូលផល-អនុផលព្រៃឈើនេះ ត្រូវបានបែងចែកដូចខាងក្រោម :

-ចំនួន ៥០ % ( ហាសិបភាគរយ) ជាចំណែកលើកទឹកចិត្តមន្ត្រីបំពេញការងារ នៃក្រសួងបរិស្ថាន ក្នុងគណៈកម្មការ

-ចំនួន ៣០ % ( សាមសិបភាគរយ ) ជាចំណែកលើកទឹកចិត្តមន្ត្រីបំពេញការងារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណៈកម្មការ

-ចំនួន ២០ % ( ម្ភៃភាគរយ ) ជាចំណែកលើកទឹកចិត្តមន្ត្រីបំពេញការងារ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគណៈកម្មការ ។

**ប្រការ៣ :**

មុនពេលបង់ចំណូលពីសួយសារផល-អនុផលព្រៃឈើ ៩៧% ( កៅសិបប្រាំពីរភាគរយ ) ចូលថវិការដ្ឋ ក្រសួងបរិស្ថានត្រូវកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៣% ( បីភាគរយ ) ។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានចាត់ទុកថាថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនក្រសួងបរិស្ថាន សម្រាប់យកទៅបែងចែកដូចបានកំណត់ក្នុងប្រការ២នៃប្រកាសនេះ ។ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធដែលបានទទួលប្រាក់រង្វាន់នេះ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីរបស់ខ្លួន នៅរៀងរាល់ពេលដែលមានការបែងចែកប្រាក់រង្វាន់ ។

**ប្រការ៤ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥ :**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មការអន្តរក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**<u>កន្លែងទទួល:</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អាជ្ញាធរសវនកម្មជាតិ
-អង្គភាពប្រឆាំងអំពើពុករលួយ
" ដើម្បីជូនជ្រាប "
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ